II-ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៥១ អនក្រ
ស្ដីពីការបង្កើត ១ កងពលតូចថ្មើរជើង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ខែវិច្ឆិកាឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការនៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : បង្កើត ១ កងពលតូចថ្មើរជើង ដោយផ្អែកលើមូលដ្ឋាន កងវរសេនាធំលេខ ៧០ ដែលកំពុង មាន បច្ចុប្បន្នហើយស្ថិតនៅក្រោមការដឹកនាំ បញ្ជាផ្ទាល់របស់អគ្គសេនាធិការ កងពលតូចថ្មើរជើងនេះ យកបញ្ញាសំគាល់ កងពលតូចថ្មើរជើងលេខ ៧០ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គ សេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យ នេះ ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
[illegible]	[illegible]